តពីទំព័រ ២៤ **ព័ត៌មានថ្មីៗ ...**

### *កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់វិស័យសាធារណៈ* (DGPSR)

កញ្ញា ធន់ វិមាលា កំពុងកែសំរួលបន្តិចបន្តួចជាចុងក្រោយ ដើម្បីបង្ហើយរបាយការណ៍សិក្សា "ការដឹកនាំនៅថ្នាក់ភូមិ/ឃុំ" ហើយក៏បានរៀបចំរួចរាល់ដែរ នូវឯកសារសង្ខេបគោលនយោបាយមួយ ផ្អែកលើរបាយការណ៍ខាងលើ ។ការសិក្សាពី"សមត្ថភាពស្រាវជ្រាវនៃសាកលវិទ្យាល័យនៅកម្ពុជា" បានចប់សព្វគ្រប់តាមផែនការ ។ ឯកសារព្រាងទី១ នៃគំរោង "អភិបាលកិច្ចថ្នាក់មូលដ្ឋានលើធនធានទ្រព្យរួមៈ ករណីសិក្សាពីទឹកស្រោចស្រពនៅកម្ពុជា" បានចប់រួចរាល់កាលពីចុងខែកក្កដា ហើយបច្ចុប្បន្ន អ្នកស្រី ជា ជូ កំពុងធ្វើការកែសម្រួលឯកសារនេះ ដោយមានកែតម្រូវផ្នែកខ្លះ ដកផ្នែកខ្លះចេញ និងដាក់បញ្ចូលថែមផ្នែកខ្លះទៀត ។ឯកសារព្រាងទី៥ស្ដីពីគំរោងផ្ដល់យោបល់ពិគ្រោះដល់គណៈកម្មាធិការជាតិ សំរាប់វិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួងមហាផ្ទៃ ដែលទទួលមូលនិធីពីវិទ្យាស្ថានសិក្សាពីទីក្រុង (Urban Institute) បានរួចរាល់មួយភាគធំ ហើយសិក្ខាសាលាផ្ដល់យោបល់ពិគ្រោះមួយផ្សេងទៀត គ្រោងធ្វើឡើងនៅខែតុលានេះ ។ សំណើគំរោង "ការយល់ដឹងពីការពាក់ព័ន្ធរវាង អង្គនីតិបញ្ញត្តិសង្គម និងស៊ីវិលនៅកម្ពុជា" ត្រូវបានដាក់ជូនទាន់ពេល ដល់វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (Overseas Development Institute) និងកំពុងរង់ចាំទទួលយោបល់ត្រលប់ ។ សំរាប់គំរោង "ការវិភាគពីរដ្ឋកម្ពុជាៈ អំណោយផលដល់ការអភិវឌ្ឍ?" ការចុះសិក្សាដល់កន្លែង គ្រោងធ្វើឡើងនៅពាក់កណ្ដាលខែតុលា ដើម្បីយកគំនិតមួយចំនួន ដែលទទួលបានពីការសិក្សាឯកសារ ទៅប្រៀបធៀបផ្ទៀងផ្ទាត់ជាមួយការពិតជាក់ស្ដែង ។ គំរោងមួយទៀតគឺ "គ្រោងការសេវាច្រកចេញចូលតែមួយ" ក្រោមជំនួយមូលនិធិពីធនាគារពិភពលោកបានទទួលការយល់ស្រប និងបានចាប់ផ្ដើមនៅដើមខែកញ្ញា ហើយត្រូវចប់សព្វគ្រប់ក្នុងរយៈពេលកំណត់ ៥ខែ ។

### *កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន*

ក្រុមអ្នកស្រាវជ្រាវនៃកម្មវិធីនេះ បានបញ្ចប់ការសំអាត និងវិភាគទិន្នន័យសំរាប់សមាសភាគសេដ្ឋកិច្ច នៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងការគ្រប់គ្រងធនធានទឹក (WRMRCDP) ។ ក្រុមស្រាវជ្រាវ ក៏បានរៀបចំវគ្គបណ្ដុះបណ្ដាលមួយ ក្រោមចំណងជើង "ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ" និងបានជួបពិភាក្សាជាមួយក្រុមអ្នកស្រាវជ្រាវ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីកសាង និងកែលំកម្មវិធីសិក្សាពីការគ្រប់គ្រងធនធានទឹក ។កម្មវិធីនេះបានរៀបចំហើយ នូវផែនការការងារឆ្នាំ២០០៩-២០១១ ។ ក្រុមការងាររបស់កម្មវិធី ក៏បានជួបជាមួយ AusAID ដើម្បីតាមដានបន្តនូវរបាយការណ៍លូតលាស់ការងារប្រចាំឆ្នាំទី៣ និងធ្វើការកែសម្រួលរបាយការណ៍នេះ ។ គំរោង "ព្រៃត្រូពិចសំរាប់កាត់បន្ថយភាពក្រីក្រ ការវិភាគទិន្នន័យពីកំរិតគ្រួសារដល់កំរិតសកល" កំពុងស្ថិតក្នុងដំណាក់កាលសំអាតទិន្នន័យ ដោយមានកិច្ចសហការជាមួយបុគ្គលិកផ្នែកគ្រប់គ្រងទិន្នន័យរបស់ CIFOR ។ ចំពោះគំរោង "ការកសាងសមត្ថភាពសហគមន៍ សំរាប់ការផ្ដួចផ្ដើមគំនិតកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប" លោក យ៉ែម ដារារដ្ឋ បានបញ្ចប់ការកែសម្រួលផែនការការងារ និងថវិកា និងបានបញ្ជូនសំណើទៅឱ្យមូលនិធិអភិវឌ្ឍន៍អាស៊ីរួចរាល់ហើយ ។ ក្រុមអ្នកស្រាវជ្រាវក្នុងកម្មវិធីនេះ ក៏បានជួបប្រជុំមួយជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូពាក់ព័ន្ធផ្សេងទៀត ដើម្បីពិភាក្សាពីផែនការការងារ និងថវិកានេះដែរ ។ សំរាប់គំរោងស្ដីពីមាគ៌ាមានចីរភាព ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្រុមអ្នកស្រាវជ្រាវបានបញ្ចប់ការសំអាត និងវិភាគទិន្នន័យ ហើយកំពុងសរសេរបង្ហើយរបាយការណ៍ ។ ក្រុមអ្នកស្រាវជ្រាវក៏បានជួបជាមួយវិទ្យាស្ថានបរិស្ថានក្រុងស្តុកហុល (SEI) ដើម្បីពិភាក្សារបន្ថែមពីការសម្របសម្រួល និងកិច្ចសហការលើសកម្មភាពស្រាវជ្រាវជាច្រើនថែមទៀត ។

### *កម្មវិធីអភិវឌ្ឍន៍សង្គម*

នៅខែកញ្ញានេះ ក្រុមអង្កេតបានចុះសិក្សាដល់កន្លែងទាក់ទងនឹងការសិក្សាគោលពីអ្នកគ្រប់គ្រងគន្លឹះ សំរាប់កម្មវិធីជួយទ្រទ្រង់វិស័យសុខាភិបាល ដោយបានធ្វើជាក់ស្ដែងនៅក្នុងមន្ទីរពេទ្យចំនួន ៣០ និងស្រុកប្រតិបត្តិ ៣០ ក្នុងខេត្តក្រុងចំនួន ២១ ។CDRI រួមជាមួយ វិទ្យាស្ថានគោលនយោបាយអ៊ុកស្វដ (OPI) និងដោយមានជំនួយគាំទ្រពីនាយកដ្ឋានសំរាប់ការអភិវឌ្ឍអន្តរជាតិ (UK-DFID) គ្រោងធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទមួយស្ដីពី "វិស័យសុខាភិបាលៈ ស្ថាប័ន សន្ទះចិត្ត និងគ្រឿងលើកទឹកចិត្ត" នៅថ្ងៃទី ២៦-២៨ មេសា ២០១០ នៅរាជធានីភ្នំពេញ ។ សន្និសីទនេះ នឹងមានការចូលរួមពីសំណាក់វាគ្មិនក្នុងប្រទេសកម្ពុជា និងមកពីបរទេស តាមរយៈកិច្ចសន្យាអនុវត្តការងារ និងលិខិតអញ្ជើញ ។ សេចក្ដីប្រកាសឱ្យដាក់ស្នើឯកសារសំរាប់សន្និសីទបានចប់សព្វគ្រប់ ហើយគណៈកម្មាធិការជ្រើសរើសនៃសន្និសីទតំបន់នេះ ក៏បានធ្វើការសំរេចចិត្តរួចហើយ ផ្អែកលើអត្ថបទសង្ខេបខ្លឹមសារនានា ។ ក្នុងចំណោម ១៤ អត្ថបទសង្ខេប ដែលបញ្ជូនមកពីតំបន់ផ្សេងៗគ្នា គេបានជ្រើសរើស ៥ សំណើ ជាឯកសារចុះកិច្ចសន្យា និង ៤ សំណើ ជាឯកសារអញ្ជើញចូលរួម ។ កម្មវិធីព្រាងនៃសន្និសីទបានរៀបចំរួចរាល់ រីឯលិខិតអញ្ជើញអ្នកដឹកនាំសំរាប់វគ្គទាំង ៥ នៃសន្និសីទ ក៏បានផ្ញើចេញស្រេចបាច់ ដោយក្នុងនេះមាន ២នាក់ បានយល់ព្រមតាមការអញ្ជើញរួចហើយដែរ ។ គំរោងស្ដីពី "សុវត្ថិភាពជនក្រីក្រនៅក្រុងភ្នំពេញៈ ការសិក្សាពីបទល្មើសព្រហ្មទណ្ឌ និងអំពើហិង្សា ក្នុង ៥ សហគមន៍ក្រីក្រនៅក្រុងភ្នំពេញ" បានចាប់ដំណើរការហើយ ។ ការសិក្សាឯកសារនៅការិយាល័យបានចប់សព្វគ្រប់ និងបានបញ្ជូនលទ្ធផលទៅអង្គការ UN-Habitat រួចហើយ ដើម្បីសុំយោបល់ ។ បញ្ជីសំនួរសំរាប់អង្កេតបានរៀបចំរួចរាល់ បានយកទៅប្រើសាកល្បងនៅថ្ងៃទី ១ តុលា ហើយបានធ្វើការកែសម្រួលតាមនោះហើយ ។ ឥឡូវនេះ ក្រុមអ្នកធ្វើអង្កេតកំពុងចុះប្រមូលទិន្នន័យដល់កន្លែង ។

ក្នុងអំឡុងពេលនេះដែរ ក្រុមបណ្តុះបណ្តាល បានដំណើការចប់រួចរាល់នូវវគ្គ "ការងារកសាងសន្តិភាព" ចំនួន ៤ ដោយបានចុះដកពិសោធន៍ជាក់ស្តែងមួយលើកនៅខេត្តកំពង់ស្ពឺទៀតផង ។ ពិធីបញ្ចប់វគ្គបណ្តុះបណ្តាលមួយ បានរៀបចំឡើងនៅថ្ងៃទី ១១ កញ្ញា ដោយមានការប្រគល់វិញ្ញាបនប័ត្រដល់សិក្ខាកាមដែលបានរៀនចប់ដោយជោគជ័យនូវវគ្គ "ការងារកសាងសន្តិភាព" និង វគ្គ "បណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល" ។ អ្នកស្រី ហ៊ុយ រំដួល ដែលបានទៅចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសម៉ាឡេស៊ី ស្តីពីសន្តិភាពនិងការដោះស្រាយទំនាស់ ក្រោមជំនួយឧបត្ថម្ភពី Church World Service បានត្រឡប់មកដល់ប្រទេសកម្ពុជាវិញហើយ ។

## *កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់*

របាយការណ៍ស្តីពី "ការទាញប្រយោជន៍ឱ្យបានប្រសើរបំផុតពីវិនិយោគចិនទៅលើធនធានធម្មជាតិនៅកម្ពុជា" កំពុងរង់ចាំយោបល់ពីម្ចាស់ជំនួយ ។ ការសិក្សាមួយផ្សេងទៀតស្តីពី "វិនិយោគចិននៅកម្ពុជា" កំពុងត្រូវបានកែសម្រួលដើម្បីបញ្ចូលនូវករណីសិក្សាចំនួន ៦ ហើយកាលពីចុងខែកញ្ញានេះ ក្រុមសិក្សាក៏បានផ្ញើរបាយការណ៍ព្រាងទី២ ជូនទៅម្ចាស់ជំនួយ (សាកលវិទ្យាល័យឈៀងម៉ៃ) ផងដែរ ។ របាយការណ៍ព្រាងលើជុំទី២ នៃ "ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើគ្រួសារនៅកម្ពុជា" ដែលជាការស្រាវជ្រាវរួមគ្នាមួយរវាងកម្មវិធីនេះ ហើយនិងកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD) នោះ បានបញ្ជូនទៅឱ្យធនាគារពិភពលោករួចរាល់ហើយ ។ សំរាប់គំរោង "ការវាយតម្លៃពីឥទ្ធិពលសេដ្ឋកិច្ច-សង្គមកិច្ចនៃមហាអនុតំបន់មេគង្គ" ដែលអនុវត្តរួមគ្នាជាមួយ PARD ហើយនិងកម្មវិធីអភិវឌ្ឍន៍សង្គម ឯកសារបំផុសគំនិតបានបញ្ជូនទៅឱ្យម្ចាស់ជំនួយរួចរាល់ហើយការចុះអង្កេតដល់កន្លែង គ្រោងចាប់ផ្តើមនៅចុងឆ្នាំនេះ ។ អត្ថបទសង្ខេបគោលនយោបាយមួយ ស្តីពី "ផលប៉ះពាល់នៃវិត្តិសេដ្ឋកិច្ចសាកលទៅលើកម្មករកាត់ដេរ និងប្រាក់ផ្ញើទៅផ្ទះ: ករណីនៅកម្ពុជា" ដែលទទួលមូលនិធិពីUNESCAP ត្រូវបានបញ្ជូនទៅម្ចាស់ជំនួយរួចរាល់ ហើយអត្ថបទសង្ខេបគោលនយោបាយ ស្តីពី "ផលប៉ះពាល់ខាងសង្គមកិច្ចនៃការរួមចុះសេដ្ឋកិច្ចសាកលទៅលើកម្ពុជា និងទៅលើភាពក្រីក្រនៅក្នុងប្រទេស" កំពុងកែសម្រួលឡើងវិញ ដើម្បីដាក់បញ្ចូលមតិយោបល់ ដែលទទួលបានពីអ្នកចូលរួមមកពីជាង ២០០ប្រទេស ក្នុងពេលធ្វើសន្និសីទនៅទីក្រុងហាណូយ ។ ជុំទី២ នៃការសិក្សាអំពី "ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល" ដែលទទួលមូលនិធិពីវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេសកំពុងជឿនលឿនទៅមុខយ៉ាងល្អ ។

កាលពីថ្ងៃទី ៧-៨ តុលា ២០០៩ បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ដោយសហការណ៍ជាមួយ CDRI បានដំណើរការសន្និសីទផ្សព្វផ្សាយថ្នាក់តំបន់មួយ ស្តីពីការសិក្សា DAN ចំនួនពីរ គឺ "ផលប្រយោជន៍ និងចំណាយសេដ្ឋកិច្ច នៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ និង "ពាណិជ្ជកម្ម កសិកម្ម ក្នុងមហាអនុតំបន់មេគង្គ" នៅសណ្ឋាគារភ្នំពេញក្រុងភ្នំពេញ ។ ការសិក្សាទាំងពីរនេះ ជាការងារសហការគ្នារវាងបណ្តាវិទ្យាស្ថានស្រាវជ្រាវឈានមុខនៅប្រទេសកម្ពុជា ឡាវ ថៃ វៀតណាម និង ខេត្តយុនណាន់ប្រទេសចិន ក្រោមជំនួយគាំទ្រពីមូលនិធិ Rockfeller ។ សន្និសីទរយៈពេលពីរថ្ងៃនេះ បានទាក់ទាញភ្ញៀវមកចូលរួម ២៣៥នាក់ ដែលមានជាអាទិ អ្នកកសាងគោលនយោបាយ ម្ចាស់ជំនួយ និងសង្គមស៊ីវិល និងដែលផ្តល់ការពិភាក្សា និងព័ត៌មានត្រឡប់សំខាន់ៗជាច្រើន ។

កាលពីថ្ងៃទី ០៩-១០ កញ្ញា ២០០៩ វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ឆ្នាំ២០០៩ ស្តីពី "ការរួមចំណែកនៃការស្រាវជ្រាវ ចំពោះគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ" បានប្រារព្ធធ្វើឡើងនៅសណ្ឋាគារកាំបូឌីយ៉ាណា ដោយទទួលបានជំនួយគាំទ្រពីវិទ្យាស្ថាន IDRC ។ សន្និសីទនេះមានបញ្ចូលបទបង្ហាញប្រកបដោយគុណភាពខ្ពស់លើ ៤ ប្រធានបទ គឺ (១) កសិកម្ម ធនធានធម្មជាតិ និងការចិញ្ចឹមជីវិតនៅជនបទក្នុងអន្តរកាល (២) សារៈសំខាន់នៃ ការអភិវឌ្ឍសេដ្ឋកិច្ចមានមូលដ្ឋានធំទូលាយ (៣) ការលើកកំពស់ការអភិវឌ្ឍសង្គមប្រកបដោយសមធម៌ និង (៤) ការពង្រឹងអភិបាលកិច្ចល្អ ។ សន្និសីទឆ្នាំនេះ សម្រេចបានជោគជ័យធំធេងដោយទទួលបានការចូលរួមយ៉ាងច្រើន និងការពេញចិត្តពីសំណាក់អ្នកចូលរួមទាំងឡាយ ដែលរួមមានរដ្ឋាភិបាល សហគមន៍ម្ចាស់ជំនួយ វិទ្យាស្ថានស្រាវជ្រាវនានា អង្គការមិនមែនរដ្ឋាភិបាល និងមជ្ឈដ្ឋានសិក្សា ។ អង្កេតវាយតម្លៃនៅចុងរបៀបវារៈបានឱ្យដឹងថា អ្នកចូលរួមភាគច្រើនមានការពេញចិត្តនឹងសន្និសីទនេះ ហើយមានបំណងចូលរួមកម្មវិធីនេះទៀតនៅឆ្នាំក្រោយ ដោយពួកគេយល់ថា កម្មវិធីនេះជាវេទិកាដ៏មានប្រយោជន៍សំរាប់ចែករំលែកព័ត៌មាន ទទួលបានចំណេះដឹងថ្មីៗពីការស្រាវជ្រាវអភិវឌ្ឍន៍ និងបង្កើតបណ្តាញទំនាក់ទំនង ។

## *កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ*

CDRI និងអង្គការ WorldFish Center បានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងលើគំរោងមួយ សំដៅកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទនៅបឹងទន្លេសាប ។ ការចុះសិក្សាដល់កន្លែងលើកទីមួយបានធ្វើឡើងនៅថ្ងៃទី ៥-១៥ តុលា ។ គំរោង "ការវាយតម្លៃពីឥទ្ធិពលសេដ្ឋកិច្ច-សង្គមកិច្ចនៃមហាអនុតំបន់មេគង្គ" សំរាប់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំពុងដំណើរការទៅមុខ ហើយសេចក្តីព្រាងឯកសារបំផុសគំនិត បានបញ្ជូនទៅ ADB រួចរាល់ហើយ ដើម្បីសុំយោបល់ត្រលប់ ។

តាំងពីឆ្នាំ២០០៧ មក CDRI បានរៀបចំយ៉ាងទៀងទាត់ ក្នុងពីរខែម្តងនូវសិក្ខាសាលាស្រាវជ្រាវស្តីពីបញ្ហាផ្សេងៗខាងអភិវឌ្ឍន៍ ក្នុងគោលដៅចែករំលែកលទ្ធផលស្រាវជ្រាវ ពង្រឹងគុណភាពស្រាវជ្រាវ កែលំអវិធីសាស្ត្រស្រាវជ្រាវ កសាងនូវគោលគំនិត និងធ្វើវិភាគលើប្រធានបទស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសិក្សាសាលាទាំងនេះមានមកពី CDRI ព្រមទាំងស្ថាប័ន និង NGOs នានានៅក្រុងភ្នំពេញ ។ សំរាប់សិក្ខាសាលានៅអំឡុងពេលនេះ អ្នកធ្វើបទបង្ហាញរបស់ CDRI មាន លោក ហ៊ីង វុត្ថា និង លោក ដួង វីរ័ត្ន រីឯអ្នកធ្វើបទបង្ហាញមកពីខាងក្រៅមាន សាស្ត្រាចារ្យ Sorpong Peou មកពីសាកលវិទ្យាល័យ Sophia University នៅប្រទេសជប៉ុន និង លោក Mith Samonn អ្នកវិភាគស្រាវជ្រាវនៅអង្គការ WorldFish Center ។ ប្រធានបទនានារួមមាន ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ច ពាណិជ្ជកម្មនិងធនធានធម្មជាតិ និងកសិកម្ម ។

# ព័ត៌មានថ្មីៗពី
# វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បន្តចូលរួមចំណែកក្នុងសន្និសីទ និងកិច្ចប្រជុំជាន់ខ្ពស់ថ្នាក់តំបន់ និងអន្តរជាតិស្តីពីផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចក្នុងតំបន់ និងជាសាកល និងអនាគតនៃសមាហរណកម្មថ្នាក់តំបន់ នៅអាស៊ីខាងកើត ។ ក្នុងខែតុលា នាយកប្រតិបត្តិនៃ វបសអ បានចូលរួមក្នុងការប្រជុំប្រចាំឆ្នាំនៃវេទិកាវិទ្យាស្ថាននៅអាស៊ីខាងកើត ដែលរៀបចំឡើងដោយវិទ្យាស្ថានកូរ៉េ សម្រាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ ។ វេទិកាជាអន្តរជាតិឆ្នាំនេះ មានប្រធានបទថា "ឆ្ពោះទៅរកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាស៊ីខាងកើតៈ ជម្រើស និងសកម្មភាពនាពេលអនាគត" នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង ។

នាយកប្រតិបត្តិរបស់វិទ្យាស្ថាន ក៏បានទៅចូលរួមសន្និសីទអន្តរជាតិរបស់អាស៊ាន + ៣ ដែលរៀបចំឡើងដោយគណៈកម្មាធិការកំណែទម្រង់ និងកិច្ចការអភិវឌ្ឍន៍ជាតិ នៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចរបស់ប្រទេសចិន ។ សន្និសីទនេះ មានប្រធានបទថា "សេដ្ឋកិច្ចអាស៊ីខាងកើតៈ វិបត្តិ ការរើបឡើងវិញ និងគោលនយោបាយឆ្លើយតប "ដែលប្រារព្ធធ្វើឡើងនៅទីក្រុងប៉េកាំង ។ លោកនាយក បានធ្វើបទបង្ហាញជារបាយការណ៍ស្តីពីប្រទេសកម្ពុជា ដែលមានបញ្ចូលព័ត៌មានថ្មីៗពីការស្រាវជ្រាវ របស់ វបសអ និងការស្រាវជ្រាវផ្សេងទៀត ព្រមទាំងអនុសាសន៍ខាងគោលនយោបាយពាក់ព័ន្ធនឹងផលប៉ះពាល់នៃវិបត្តិ ហើយនិងយុទ្ធសាស្ត្រ សម្រាប់ធ្វើឱ្យប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចឡើងវិញ និងមានការអភិវឌ្ឍប្រកបដោយចីរភាព ។ សន្និសីទនៅទីក្រុងប៉េកាំង ក៏បានបង្កើតនូវបណ្តាញស្រាវជ្រាវខាងគោលនយោបាយ និងអ្នកព្យាករណ៍ផ្លូវការនៅអាស៊ីខាងកើត ដែល វបសអ នឹងចូលរួមជាសមាជិកដែរ ។

នៅខែវិច្ឆិកា វបសអ នឹងរួមសហការជាមួយសមាគមសេដ្ឋកិច្ចកម្ពុជា ដើម្បីរៀបចំសន្និសីទប្រចាំឆ្នាំលើកទី៣៤ របស់សហព័ន្ធសមាគមសេដ្ឋកិច្ចអាស៊ាន ។ សន្និសីទនេះ មានប្រធានបទថា "ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកលទៅលើបណ្តាប្រទេសអាស៊ាន និងវិធីសាស្ត្រកាត់បន្ថយផលប៉ះពាល់ទៅលើប្រជាជនក្រីក្រ" ។

នៅដើមខែធ្នូ វបសអ នឹងសម្រាកដកឃ្លាទៅប្រជុំថ្នាក់គ្រប់គ្រង-បុគ្គលិកប្រចាំឆ្នាំរយៈពេលពីរថ្ងៃនៅខេត្តកោះកុងដើម្បីឆ្លុះបញ្ចាំងលើមេរៀននៃសមិទ្ធផលដែលទទួលបានក្នុងឆ្នាំ២០០៩ អាទិភាពសម្រាប់ឆ្នាំ២០១០ និងការស្រាវជ្រាវសំខាន់ៗ ព្រមទាំងគោលនយោបាយដែលគួរដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រស្រាវជ្រាវពីប្រទេសកម្ពុជា របស់ វបសអ ។ យុទ្ធសាស្ត្រនេះនឹងក្លាយជាក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៥ របស់ វបសអ ។

## ផ្នែកស្រាវជ្រាវ

ពីខែតុលា ដល់ ខែធ្នូ ២០០៩ CDRI អនុវត្តសកម្មភាពស្រាវជ្រាវមួយចំនួនដែលមានជាសង្ខេបដូចតទៅៈ

(តទៅទំព័រ ២២)

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០០៩

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធីរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ វ៉ា វណ្ណៈ និង ខេង សេង
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៩ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។